
សៀវភៅណែនាំ
ស្តីពី
ស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ



User Manual
Hotel Ratings Plaque Design

គណៈកម្មការរៀបចំចំណាត់ថ្នាក់សណ្ឋាគារ

២០១៥

មាតិកា

- ប្រកាសស្តីពីស្លាកសញ្ញាចំណាត់ថ្នាក់
- មនោភាពនៃស្លាកសញ្ញាចំណាត់ថ្នាក់
- ទម្រង់នៃស្លាកសញ្ញាចំណាត់ថ្នាក់
- ខ្លឹមនៃស្លាកសញ្ញាចំណាត់ថ្នាក់
- ប្រភេទគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ និងQR CODE

ប្រកាសស្តីពីស្លាកសញ្ញាចំណាត់ថ្នាក់



ប្រកាស

ស្តីពី

គំរូស្ថាពសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ មិថុនា ឆ្នាំ២០០៩ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៦ អនក្រ.បក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

សេចក្តីប

ប្រការ ១._

ប្រកាសនេះមានគោលបំណងដាក់ចេញនូវគំរូស្តាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ដូចមានក្នុងអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍។

ប្រការ ២._

ស្តាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារត្រូវអនុលោមតាមគំរូនៃឧបសម្ព័ន្ធដែលមានចែងក្នុងប្រកាសនេះ។

រាល់ចំណាយក្នុងការផលិតស្តាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារជាបន្ទុករបស់ម្ចាស់សណ្ឋាគារ។

ប្រការ ៣._

ការតាំង ឬផ្សព្វផ្សាយស្តាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារដែលមិនអនុលោមតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ត្រូវទទួលពិន័យទៅតាមច្បាប់ស្តីពីទេសចរណ៍ និងអនុក្រឹត្យលេខ១៦ អនក្រ.បក និងបទដ្ឋានគតិយុត្តិផ្សេងទៀតជាធរមាន។

ប្រការ ៤._

រាល់សណ្ឋាគារទាំងឡាយណា ដែលទទួលបានចំណាត់ថ្នាក់មុនកាលបរិច្ឆេទនៃប្រកាសនេះចូលជាធរមាន ត្រូវបន្តអនុវត្តទៅតាមគំរូនៃប្រកាសស្តីពីគំរូស្តាកសញ្ញាចំណាត់ថ្នាក់ចាស់រហូតដល់ថ្ងៃអស់សុពលភាពនៃចំណាត់ថ្នាក់នោះ។

ប្រការ ៥._

ប្រកាសរបស់ក្រសួងទេសចរណ៍លេខ ១០៦ ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីគំរូស្តាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ផ្កាយ១ ផ្កាយ២ ផ្កាយ៣ ផ្កាយ៤ ផ្កាយ៥ ត្រូវទុកជានិរាករណ៍។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៦._


អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានក្រុមអ្នកច្បាប់ អធិការ គ្រប់ប្រធាននាយកដ្ឋាន ប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្លៃមាន្ត្រី

ហ៊ោ ខុន


កន្លែងទទួល:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
-សាលារាជធានីខេត្ត
-សមាគមសណ្ឋាគារ
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

មនោសាពនៃស្លាកសញ្ញាចំណាត់ថ្នាក់



គំរូស្លាកចំណាត់ថ្នាក់សណ្ឋាគារថ្មីនេះគឺ:

កើតចេញពីទស្សនៈនៃការយកក្រដាស់១សន្លឹកមកធ្វើការបត់បង្កើតបានជាទម្រង់ ដូចជាការយកក្រដាសរឹង១សន្លឹកដែលតំណាងអោយសំបុត្រសកជាក់ចូលក្នុងប្រអប់សំបុត្រដែលត្រូវបានគេភ្ជាប់នឹងជញ្ជាំងនៅច្រកចូលរបស់កន្លែងស្នាក់អាស្រ័យណាមួយ ។




ប្រភេទនៃការរចនា:

១. ផ្ទៃក្រដាសរឹងតំណាងអោយសំបុត្រ:


ប្រើការរចនាផ្ទៃដោយយកក្បាច់អង្គរចំលងចេញពីជញ្ជាំងប្រាសាទនៅតំបន់អង្គរ ។

២. ផ្ទៃតំណាងអោយប្រអប់សំបុត្រ:

ប្រើការរចនាផ្ទៃដោយយកទម្រង់ពណ៌មាសចាស់ដោយមានគែមព័ទ្ធជុំវិញពណ៌ស ។



ទម្រង់នៃស្លាកសញ្ញាចំណាត់ថ្នាក់



ឧទ្ទេសស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

ក្នុងបំណងពង្រឹងវិស័យឧស្សាហកម្មសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ និងងាយស្រួលដល់ភ្ញៀវទេសចរ សម្តាល់បានអំពីប្រភេទចំណាត់ថ្នាក់សណ្ឋាគារព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍សម្រេចកំណត់អំពីខ្លាត គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ ដូចខាងក្រោម៖

១- វត្ថុធាតុដើមនៃស្លាកសញ្ញា :

- ផ្នែកសុីម : ធ្វើអំពីសន្លឹកអាលុយមីញ៉ូម
- ផ្នែកផ្ទៃខាងក្រោម : ធ្វើអំពីសន្លឹកអាគ្រីលិក កម្រាស់ ៣មម ពណ៌សរ
- ផ្នែកផ្ទៃខាងលើ : ធ្វើអំពីសន្លឹកអាគ្រីលិកថ្លា កម្រាស់ ២មម
- ផ្នែកអក្សរ "H" និងផ្កាយផុស : ធ្វើអំពីសន្លឹកអាគ្រីលិក កម្រាស់ ៤មម ដោយមានសន្លឹកដែកពណ៌ទឹកមាសកម្រាស់ ០.៨មម រាងជាអក្សរ "H" ផ្កាយ និងនិមិត្តសញ្ញាបិទផ្នែកខាងលើ។

២- ទម្រង់ស្លាកសញ្ញា :

ទម្រង់ស្លាកសញ្ញារាងបួនជ្រុងទ្រវែងបញ្ឈរ

៣- ទំហំស្លាកសញ្ញា :

មានបណ្តោយ៤០.០០ សម x ទទឹង ៣០.០០ សម

៤- របៀបរចនាស្លាកសញ្ញា :

ក - ផ្ទៃស្លាកសញ្ញា (ក្រៅពីផ្ទៃអក្សរ "H" រូបផ្កាយ ផ្ទៃអក្សរឈ្មោះសណ្ឋាគារ និងលេខសុពលភាព) គឺជាផ្ទៃអាគ្រីលិកដោយមានបិទរូបពោះពុម្ពរលោងជាក្បាច់ជញ្ជាំងថ្មអង្គរ

ខ - តួអក្សរផុស "H" តំណាងឲ្យសេវាសណ្ឋាគារ គឺជាផ្ទៃអាគ្រីលិកពណ៌សរ កម្រាស់ ៤មម ដោយមានបិទសន្លឹកដែកពណ៌ទឹកមាសនៅខាងលើ

គ - រូបផ្កាយផុសតំណាងឲ្យចំណាត់ថ្នាក់សណ្ឋាគារ គឺជាផ្ទៃអាគ្រីលិកកម្រាស់៤មមដោយមានបិទសន្លឹកដែកពណ៌ទឹកមាសនៅខាងលើ

ឃ - តួអក្សរឈ្មោះសណ្ឋាគារ និងលេខសុពលភាពចំណាត់ថ្នាក់ជាផ្ទៃពោះពុម្ពរលោងមានពណ៌ទឹកបិចស្រស់

ង - ផ្ទៃនិមិត្តសញ្ញាស្តាប់ន គឺជាផ្ទៃអាគ្រីលិកកម្រាស់៤មមដោយមានបិទសន្លឹកដែកពណ៌ទឹកមាសនៅខាងលើ

ច - តួអក្សរខ្មែរ "ក្រសួងទេសចរណ៍" ជាប្រភេទតួអក្សរឆ្លាក់លាបពណ៌ទឹកបិចស្រស់

ឆ - តួអក្សរអង់គ្លេស "Ministry of Tourism" ជាប្រភេទតួអក្សរឆ្លាក់លាបពណ៌ទឹកបិចស្រស់

ជ - រូបនិមិត្តសញ្ញាស្តាប់ន គឺជាផ្ទៃឆ្លាក់លាបពណ៌ក្រហម និងពណ៌ទឹកបិចស្រស់។

៥- អំពីទំហំផ្ទៃស្លាកសញ្ញា តួអក្សរ និងរូបផ្កាយ :

ក - ផ្ទៃផ្ទៃកខាងលើមានរូបថ្មជញ្ជាំងអង្គរលោង មានទំហំ ៣០០ មម x៣១០ មម

ខ- តួអក្សរ "H" មានទំហំ ១២៥ មម x ៩៥ មម

គ- រូបផ្កាយកំពូលព្រាំ ទំហំ ៤៥ មម x ៤៥ មម

ឃ- តួអក្សរឈ្មោះសណ្ឋាគារជាអក្សរឡាតាំង ទំហំអាចប្រែប្រួលទៅតាមចំនួនតួអក្សរតែត្រូវតួចជាងអក្សរ "H"

ង- លេខសុពលភាពឆ្នាំ ទំហំ ៥៥ មម x ១០ មម

ច- ផ្ទៃផ្ដែកខាងក្រោមសម្រាប់និមិត្តសញ្ញាក្រសួង ទំហំ ៣០០ មម x ១១០ មម

ឆ- និមិត្តសញ្ញារបស់ស្ថាប័ន ចេញសេចក្ដីសម្រេចទទួលស្គាល់ចំណាតថ្នាក់សណ្ឋាគារ រួមមានអក្សរ "ក្រសួងទេសចរណ៍" សរសេរជាភាសាខ្មែរ, អក្សរ "Ministry of Tourism" សរសេរជាភាសាអង់គ្លេស និងរូបនៃនិមិត្តសញ្ញាស្ថាប័ន មានទំហំសរុប ៨០ មម x ៥០ មម។

៦- គម្លាតរវាងជួរនីមួយៗ :


ក/ - គម្លាតពីលើចុះក្រោម :

- ពីគែមស្លាកខាងលើនៃស្លាកសញ្ញាដល់កំពូលតួអក្សរ "H" មានគម្លាត ៧០ មម
- ពីផ្ទៃផ្ដែកខាងក្រោមតួអក្សរ "H" ដល់ផ្ទៃផ្ដែកខាងលើរូបផ្កាយមានគម្លាត ៣៥ មម
- ពីផ្ទៃផ្ដែកខាងក្រោមរូបផ្កាយដល់ផ្ទៃផ្ដែកខាងលើអក្សរឈ្មោះសណ្ឋាគារមានគម្លាត ៣៥មម
- ពីផ្ទៃផ្ដែកខាងក្រោមតួអក្សរឈ្មោះសណ្ឋាគារដល់ផ្ទៃផ្ដែកខាងលើលេខសុពលភាពមានគម្លាត ១០មម
- ពីផ្ទៃផ្ដែកខាងក្រោមលេខឆ្នាំសុពលភាពដល់ផ្ទៃផ្ដែកខាងលើគែមនៃផ្ទៃសម្រាប់និមិត្តសញ្ញារបស់ស្ថាប័ន មានគម្លាត ១០ មម
- ពីគែមខាងលើនៃផ្ទៃខាងក្រោយសម្រាប់និមិត្តសញ្ញាស្ថាប័ន ដល់ផ្ទៃផ្ដែកខាងលើនិមិត្តសញ្ញារបស់ស្ថាប័នត្រង់តួអក្សរ "ក្រសួងទេសចរណ៍" មានគំលាត ១៥ មម
- ពីផ្ទៃផ្ដែកខាងក្រោមនៃនិមិត្តសញ្ញារបស់ស្ថាប័នត្រង់តួអក្សរ "Ministry of Tourism" ដល់គែមខាងក្រោមនៃស្លាកសញ្ញាមានគម្លាត ១៥ មម។

ខ/ - គម្លាតពីគែមសងខាង :

- តួអក្សរ "H" មានគម្លាតពីគែមខាងស្ដាំ ៥០ មម
- រូបផ្កាយនៅចន្លោះកណ្ដាល និងមានគម្លាតពីគែមសងខាងអាស្រ័យលើចំនួនផ្កាយ
- តួអក្សរឈ្មោះសណ្ឋាគារនៅចន្លោះកណ្ដាល និងមានគម្លាតពីគែមស្តាំសងខាងដោយអាស្រ័យលើប្រវែងនៃតួអក្សរ
- លេខសុពលភាពនៅចន្លោះកណ្ដាល និងមានគម្លាតពីគែមសងខាង ១២២.៥ មម
- និមិត្តសញ្ញារបស់ស្ថាប័ននៅចន្លោះកណ្ដាល និងមានគម្លាតពីគែមសងខាង ១១០ មម។

លក្ខណៈនៃស្លាកសញ្ញាចំណាត់ថ្នាក់




អក្សរផ្កាយតំណាងនិមិត្តរូបសណ្ឋាគារ

រូបផ្កាយផ្ទុះតំណាងចំណាត់ថ្នាក់សណ្ឋាគារ

ឈ្មោះសណ្ឋាគារ និងរយៈពេលសុពលភាព


និមិត្តសញ្ញាក្រសួងទេសចរណ៍

ខ្លាតង៉ែស្លាកសញ្ញាចំណាត់ថ្នាក់



ខ្នាតគំនាប់ : ខ្នាតគិតជាមីលីម៉ែត្រ
ជើងចាប់ភ្ជាប់ផ្ដាក់
ផ្ទៃជញ្ជាំងមានស្រាប់
NAME OF HOTEL
2015-2017
400
260
70
20
50
125
95
15
80
110
55
230
300

ប្រភេទគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ និងQR CODE



គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយចែកជា៥ចំណាត់ថ្នាក់គឺ



១. ស្លាកសញ្ញា
ចំណាត់ថ្នាក់
សណ្ឋាគារផ្កាយ ១



២. ស្លាកសញ្ញា
ចំណាត់ថ្នាក់
សណ្ឋាគារផ្កាយ ២



៣. ស្លាកសញ្ញា
ចំណាត់ថ្នាក់
សណ្ឋាគារផ្កាយ ៣



៤. ស្លាកសញ្ញា
ចំណាត់ថ្នាក់
សណ្ឋាគារផ្កាយ ៤




៥. ស្លាកសញ្ញា
ចំណាត់ថ្នាក់
សណ្ឋាគារផ្កាយ ៥

គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ១

បន្ទះស្លាកសញ្ញាធ្វើអំពីសន្លឹកអាក្រិលិកថ្លាពីរជាន់ ដែលមានកម្រាស់សរុប៥មម និងមានទំហំ ៤០០មម x ៣០០មម ផ្នែកខាងក្រោមមានផ្ទៃពណ៌ទឹកមាសគឺមានកាត់ជ្រុងផ្នែកខាងស្តាំរាងជាត្រីកោណដែលមានប្រវែង៥៣មម និង៧៤មម ផ្ទៃផ្នែកខាងលើដែលមានអក្សរ និង រូបផ្កាយផុសប្រកបដោយរូបក្បាច់រំលេចពីខាងក្រោយរួមនឹងផ្ទៃផ្នែកខាងក្រោម គឺជាផ្ទៃរលោងថ្លាដោយមានតែមពណ៌ស។ បន្ទះស្លាកសញ្ញាគឺត្រូវបានភ្ជាប់និងជញ្ជាំងដែលមានស្រាប់ដោយប្រើដែកអ៊ីណុកភ្ជាប់រាងមូលដែលមានទំហំ ៦មម ដោយឱ្យឃ្លាតពីជញ្ជាំងចន្លោះប្រវែង ២០មម។

ពណ៌បៃតងស្រាល	Code: (c38 m1 y50 k0)	ផ្ទៃសន្លឹកផ្នែកខាងលើ
ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃសន្លឹកផ្នែកខាងក្រោម
ពណ៌ស	Code: (c0 m0 y0 k0)	ផ្ទៃតែមខាងក្រៅនៃផ្ទៃសន្លឹកផ្នែកខាងក្រោម ផ្ទៃតែមខាងក្រៅអក្សរតំណាងសណ្ឋាគារ
ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃអក្សរតំណាងសណ្ឋាគារនិងផ្កាយ
ពណ៌ក្រហម	Code: (c0 m100 y100 k0)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង
ពណ៌ខៀវចាស់	Code: (c99 m97 y3 k1)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង ផ្ទៃអក្សរសំគាល់រយៈពេលសុពលភាព



កំណត់សំគាល់ : ខ្នាតគិតជាមីលីម៉ែត្រ

គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ២

បន្ទះស្លាកសញ្ញាធ្វើអំពីសន្លឹកអាក្រិលិកថ្លាពីរជាន់ ដែលមានកម្រាស់សរុប៥មម និងមានទំហំ ៤០០មម x ៣០០មម ផ្នែកខាងក្រោមមានផ្ទៃពណ៌ទឹកមាសគឺមានកាត់ផ្រុងផ្នែកខាងស្តាំរាងជាត្រីកោណដែលមានប្រវែង៥៣មម និង៧៤មម ផ្ទៃផ្នែកខាងលើដែលមានអក្សរ និង រូបផ្កាយផុសប្រកបដោយរូបក្បាច់រំលេចពីខាងក្រោយរួមនឹងផ្ទៃផ្នែកខាងក្រោមគឺជាផ្ទៃរលោងថ្លាដោយមានតែមពណ៌ស។ បន្ទះស្លាកសញ្ញាគឺត្រូវបានភ្ជាប់និងជញ្ជាំងដែលមានស្រាប់ដោយប្រើដែកអ៊ីណុកភ្ជាប់រាងមូលដែលមានទំហំ ៦មម ដោយឱ្យឃ្លាតពីជញ្ជាំងចន្លោះប្រវែង ២០មម។

	ពណ៌បៃតងស្រាល	Code: (c38 m1 y50 k0)	ផ្ទៃសន្លឹកផ្នែកខាងលើ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃសន្លឹកផ្នែកខាងក្រោម
	ពណ៌ស	Code: (c0 m0 y0 k0)	ផ្ទៃតែមខាងក្រៅនៃផ្ទៃសន្លឹកផ្នែកខាងក្រោម ផ្ទៃតែមខាងក្រៅអក្សរតំណាងសណ្ឋាគារ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃអក្សរតំណាងសណ្ឋាគារនិងផ្កាយ
	ពណ៌ ក្រហម	Code: (c0 m100 y100 k0)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញា ក្រសួង
	ពណ៌ខៀវចាស់	Code: (c99 m97 y3 k1)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញា ក្រសួង ផ្ទៃអក្សរសំគាល់រយៈពេលស្មុគស្មាញ



កំណត់សំគាល់ : ខ្នាតគិតជាមីលីម៉ែត្រ

គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ៣

បន្ទះស្លាកសញ្ញាធ្វើអំពីសន្លឹកអាក្រិលិកថ្លាពីរជាន់ ដែលមានកម្រាស់សរុប៥មម និងមានទំហំ ៤០០មម x ៣០០មម ផ្នែកខាងក្រោមមានផ្នែកពណ៌ទឹកមាសគឺមានកាត់ជ្រុងផ្នែកខាងស្តាំរាងជាក្រឹកោណដែលមានប្រវែង៥៣មម និង៧៤មម ផ្នែកផ្នែកខាងលើដែលមានអក្សរ និង រូបផ្កាយផុសប្រកបដោយរូបក្បាច់រំលេចពីខាងក្រោយរួមនឹងផ្នែកផ្នែកខាងក្រោម គឺជាផ្នែរលោងថ្លាដោយមានតែមពណ៌ស។ បន្ទះស្លាកសញ្ញាគឺត្រូវបានភ្ជាប់នឹងជញ្ជាំងដែលមានស្រាប់ដោយប្រើដែកអ៊ីណុកភ្ជាប់រាងមូលដែលមានទំហំ ៦មម ដោយឱ្យឃ្លាតពីជញ្ជាំងចន្លោះប្រវែង ២០មម។

	ពណ៌បៃតងស្រាល	Code: (c38 m1 y50 k0)	ផ្នែសន្លឹកផ្នែកខាងលើ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្នែសន្លឹកផ្នែកខាងក្រោម
	ពណ៌ស	Code: (c0 m0 y0 k0)	ផ្នែតែមខាងក្រៅនៃផ្នែសន្លឹកផ្នែកខាងក្រោម ផ្នែតែមខាងក្រៅអក្សរតំណាងសណ្ឋាគារ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្នែអក្សរតំណាងសណ្ឋាគារនិងផ្កាយ
	ពណ៌ក្រហម	Code: (c0 m100 y100 k0)	ផ្នែមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង
	ពណ៌ខៀវចាស់	Code: (c99 m97 y3 k1)	ផ្នែមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង ផ្នែអក្សរសំគាល់រយៈពេលស្មុគស្មាញ




កំណត់សំគាល់ : ខ្នាតគិតជាមីលីម៉ែត្រ

គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ៤

បន្ទះស្លាកសញ្ញាធ្វើអំពីសន្លឹកអាក្រិលិកថ្លាពីរជាន់ ដែលមានកម្រាស់សរុប៥មម និងមានទំហំ ៤០០មម x ៣០០មម ផ្នែកខាងក្រោមមានផ្ទៃពណ៌ទឹកមាសគឺមានកាត់ជ្រុងផ្នែកខាងស្តាំរាងជាត្រីកោណដែលមានប្រវែង៥៣មម និង៧៤មម ផ្ទៃផ្នែកខាងលើដែលមានអក្សរ និង រូបផ្កាយផុសប្រកបដោយរូបក្បាច់រំលេចពីខាងក្រោយរួមនឹងផ្ទៃផ្នែកខាងក្រោមគឺជាផ្ទៃរលោងថ្លាដោយមានតែមពណ៌ស។ បន្ទះស្លាកសញ្ញាគឺត្រូវបានភ្ជាប់និងជញ្ជាំងដែលមានស្រាប់ដោយប្រើដែកអ៊ីណុកភ្ជាប់រាងមូលដែលមានទំហំ ៦មម ដោយឱ្យឃ្លាតពីជញ្ជាំងចន្លោះប្រវែង ២០មម។

	ពណ៌មាសខ្ចី	Code: (c0 m24 y85 k15)	ផ្ទៃសន្លឹកផ្នែកខាងលើ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃសន្លឹកផ្នែកខាងក្រោម
	ពណ៌ស	Code: (c0 m0 y0 k0)	ផ្ទៃតែមខាងក្រៅនៃផ្ទៃសន្លឹកផ្នែកខាងក្រោម ផ្ទៃតែមខាងក្រៅអក្សរតំណាងសណ្ឋាគារ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃអក្សរតំណាងសណ្ឋាគារនិងផ្កាយ
	ពណ៌ ក្រហម	Code: (c0 m100 y100 k0)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង
	ពណ៌ខៀវចាស់	Code: (c99 m97 y3 k1)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង ផ្ទៃអក្សរសំគាល់រយៈពេលសុពលភាព



កំណត់សំគាល់: ខ្នាតគិតជាមីលីម៉ែត្រ

គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារផ្កាយ៥

បន្ទះស្លាកសញ្ញាធ្វើអំពីសន្លឹកអាក្រិលិកថ្លាពីរជាន់ ដែលមានកម្រាស់សរុប៥មម និងមានទំហំ ៤០០មម x ៣០០មម ផ្នែកខាងក្រោមមានផ្ទៃពណ៌ទឹកមាសគឺមានកាត់ច្រុងផ្នែកខាងស្តាំរាងជាត្រីកោណដែលមានប្រវែង៥៣មម និង៧៤មម ផ្ទៃផ្នែកខាងលើដែលមានអក្សរ និង រូបផ្កាយផុសប្រកបដោយរូបក្បាច់រំលេចពីខាងក្រោយរួមនឹងផ្ទៃផ្នែកខាងក្រោមគឺជាផ្ទៃរលោងថ្លាដោយមានគែមពណ៌ស។ បន្ទះស្លាកសញ្ញាគឺ ត្រូវបានភ្ជាប់នឹងជញ្ជាំងដែលមានស្រាប់ដោយប្រើដែកអ៊ីណុកភ្ជាប់រាងមុំដែលមានទំហំ ៦មម ដោយឱ្យឃ្លាតពីជញ្ជាំងចន្លោះប្រវែង ២០មម។

	ពណ៌មាសខ្ចី	Code: (c0 m24 y85 k15)	ផ្ទៃសន្លឹកផ្នែកខាងលើ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃសន្លឹកផ្នែកខាងក្រោម
	ពណ៌ស	Code: (c0 m0 y0 k0)	ផ្ទៃគែមខាងក្រៅនៃផ្ទៃសន្លឹកផ្នែកខាងក្រោម ផ្ទៃគែមខាងក្រៅអក្សរតំណាងសណ្ឋាគារ
	ពណ៌មាសចាស់	Code: (c0 m27 y94 k45)	ផ្ទៃអក្សរតំណាងសណ្ឋាគារនិងផ្កាយ
	ពណ៌ក្រហម	Code: (c0 m100 y100 k0)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង
	ពណ៌ខៀវចាស់	Code: (c99 m97 y3 k1)	ផ្ទៃមួយផ្នែកនៃនិមិត្តសញ្ញាក្រសួង ផ្ទៃអក្សរសំគាល់រយៈពេលស្មុគស្មាញ



កំណត់សំគាល់: ខ្នាតគិតជាមីលីម៉ែត្រ


QR CODE សម្រាប់គំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារ

ប្រភេទគំរូស្លាកសញ្ញាចំណាត់ថ្នាក់សណ្ឋាគារថ្មីនេះ គឺមានបង្កប់នូវលេខ QR Code បិទនៅផ្នែកខាងក្រោយនៃសន្លឹកគំរូស្លាកសញ្ញាចំណាត់ថ្នាក់នេះ។ QR Code នេះគឺជាមានបង្កប់នូវព័ត៌មានលំអិតទាក់ទងនឹងសណ្ឋាគារដែលទទួលបានចំណាត់ថ្នាក់។ ការបង្កប់នូវ QR Code នេះមានគោលបំណងដើម្បីធានានូវភាពស្របច្បាប់ និងភាពត្រឹមត្រូវនៃចំណាត់ថ្នាក់របស់ប្រតិបត្តិករសណ្ឋាគារដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច។

QR Code បង្ហាញនូវព័ត៌មានដូចជា:

- ឈ្មោះសណ្ឋាគារ
- ចំណាត់ថ្នាក់សណ្ឋាគារ
- ទីតាំងសណ្ឋាគារ





លេខ QR Code បិទនៅផ្នែកខាងក្រោយនៃសន្លឹកគំរូស្លាកសញ្ញា


H
Sofitel Hotel
2015-2017
MINISTRY OF TOURISM

ជីឡូត៍លេខ៣A ផ្លូវលេខ ១៦៩ សង្កាត់៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ:+៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤
E-mail: admin@mot.gov.kh
Website: www.mot.kh